# ឯកសាររបស់អេក្អូអាស៊ី

**អាងទប់ទឹក "កូនអូពោះវៀនមាន់ ការចែកចាយមានប្រសិទ្ធិភាព និងការគ្រប់គ្រងទឹក ប្រយុទ្ធប្រឆាំងនឹងវិបត្តិ ការផ្គត់ផ្គង់ដោយខ្លួនឯង"**

*បកប្រែដោយ លោក សៀម ស៊ុន*

*" នៅឆ្នាំនេះទឹកនៅក្នុងទំនប់ទឹក ផាសាក់ចូឡាសុិត រ៉ាក់មែនទែនដែលអ្នកអាចឃើញប្រាសាទបាក់បែក ដើមឈើ និងអាគារចាស់ៗ ទាំងអស់។ វាជាវិបត្តិទឹកដ៏ធ្ងន់ធ្ងរតែបើវានៅតែបន្តរកន្លះខែទៀតដោយអត់មានភ្លៀងទេ វិបត្តិនេះនឹងកាន់តែធ្ងន់ធ្ងរឡើង។ ដោយសារតែយើងអត់មានទឹកល្អ យើងមិនអាចសាងសង់ការងារទឹកឡើយ យើងមិនអាចផលិតទឹកផឹកបាន ទឹកមានសារៈសំខាន់ណាស់ ទាំងការប្រើប្រាស់ហូបចុកនិងទូទៅ។ យើងបានធ្វើយុទ្ធនាការ៩ថ្ងៃពីបញ្ហាមួយ គឺទឹក ដោយសារតែកន្លែងខ្លះអត់មានទឹកទេសំរាប់ងូតឬចំអិតអាហារ វាពិតជាវិបត្តិមែន។*

យើងបានទៅសុំទឹកពីអ្នកដទៃ តែពួកគេមិនមានដែរ វិបត្តិនេះអីក៏ធំម្លេះ " នេះគឺជាពាក្យសំដីចេញពីអ្នកនៅអាងទឹកផាសាក់ទាក់ទងនឹងស្ថានភាពនៃវិបត្តិទឹកនៅឆ្នាំនេះ។ ទោះជាយ៉ាងណាក៏ដោយក៏នៅមានវិធីក្នុងការគ្រប់គ្រងដីរបស់យើងដែរដើម្បីអោយយើងអាចរស់រានមានជីវិត្តពីគ្រោះរាំងស្ងួតដូចនេះ ដោយការធ្វើជាគំរូកូនភ្នំ អាងត្រពាំងទឹក និង ស្រែ" គំរូនេះត្រូវបានយកមកអនុវត្តន៍នៅភូមិណងណូ ស្រុកមឿង ខេត្ត សារ៉ាក់បូរី។

*"សំរាប់តំបន់នេះពេលនេះយើងអាចគណនាបានថាយើងអាចប្រមូលទឹកបាន៣០០% ដំបូងពីទឹកភ្លៀង ទីពីរ ពីការបង្ហូរពីធារាសាស្រ្ត និងទីបី ទឹកពីប្រជាជនដែលមិនបានប្រមូលវាទុក ដែលគាត់មិនមានអាតស្តុកទុក។ ករណីនេះអាចអោយយើងបញ្ចេញទឹកនិងចែកចាយទឹកទៅដល់កសិដ្ឋានយើងទាំងមូលបាន " លោក ប៊ុនលោម តៅកែវ*

## ការធ្វើតែកសិកម្មស្រូវមានន័យថាជាបំណុល

កសិកម្មចំរុះមានន័យថាជីវភាពរស់នៅមាននិរន្តរភាព

លោក ប៊ុនលោម តៅកែវ គឺជាកូនកសិករស្រូវម្នាក់ដែលបានជ្រើសរើអាជីពជាអ្នកជំនួញបន្ទាប់ពីគាត់បានបញ្ចប់ការសិក្សា។ ដោយសារតែគាត់មិនអាចនឹងរកបានគ្រប់គ្រាន់ដើម្បីចិញ្ចឹមជីវិត គាត់បានជំពាក់បំណុលគេរាប់រយពាន់បាត។ដូច្នេះគាត់ក៏បានខ្ចីលុយពីឪពុករបស់គាត់ ដែលជាកសិករ

ប្រើប្រាស់វិធីសាស្ត្រកសិកម្មចំរុះ ជាច្រើនលើកច្រើនសារដើម្បីសងបំណុលរបស់ គាត់ រហូតដល់ឪពុកគាត់បាននិយាយអោយគាត់ដូរទៅជាកសិករវិញទៅ។ លោកប៊ុនលោម ក៏សំរេចចិត្តរើសយកដំបូន្មាននេះ តែគាត់នៅមិនទានជឿថាកសិកម្មអាចជួយគាត់អោយសង បំណុលបានឡើយ។ គាត់ចាប់ផ្តើមដោយការសាងសង់រចនាសម្ព័ន្ធគ្រោងដើម្បីដាំដុះផ្សិតខ្យង ដែលមិនត្រូវការការវិនិយោគធំឡើយ ហើយបន្តិតម្តងៗគាត់ចាប់ផ្តើមផលិតបានគ្រប់គ្រាន់ក្នុងការចែកចាយទៅក្នុងតំបន់ ជួយកាត់បន្ថយថ្លៃចាយវាយរបស់គាត់ រហូតដល់មានលុយគ្រប់គ្រាន់ហើយនៅសល់លុយសន្សំ ហើយរហូតដល់ចុងបញ្ចប់ គាត់អាចសងបំណុលរបស់គាត់បាន។ ជីវិតដ៏មានចីរភាពរបស់គាត់ចាប់ផ្តើមបាន១០ឆ្នាំមកហើយ។ វាគឺជាលទ្ធផលនៃការធ្វើតាមគន្លងរបស់ព្រះមហាក្សត្ររបស់គាត់ និងឪពុករបស់គាត់ ដែលជាអ្នកគំរូដល់គាត់ធ្វើតាម។

ត្រឡប់ទៅ២៥ឆ្នាំមុនហើយមើលទៅលើដីដែលគាត់មានចំនួន២០រ៉ៃ នៅជិតមជ្ឈមណ្ឌលអប់រំសេដ្ឋកិច្ចដើម្បីប្រយោជន៍ខ្លួនឯង។ នេះជាដីដែលធ្លាប់តែប្រើប្រាស់សំរាប់ដាំស្រូវដែលបានប្រើប្រាស់ជីគីមីជាច្រើនមុខ ពេលវាមានភ្លៀងវានឹងមានទឹកគ្រប់គ្រាន់ ស្រូវគ្រប់គ្រាន់ដែលអាចលក់បានដើម្បីជីវិតរស់និងសងបំណុល តែបើមានឆ្នាំណាដែលរាំងស្ងួតវិញ បំណុលនិងគរឡើង ពួកគាតកាន់តែធ្វើកសិកម្ម គឺកាន់តែជំពាក់បំណុលគេ ដូច្នេះលោក ប៊ុនលើ តាវកែវ ដែលជាមេគ្រួសារ បានសំរេចចិត្តឈប់ជួលដីបន្ថែមហើយផ្តោតសំខាន់ទៅលើតែកំរៃប្រយោជន៍ដែលបានពីដី២០រ៉ៃតែប៉ុណ្ណោះដែលគាត់មាន។

គាត់បានធ្វើដូច្នេះដោយការស្តាប់ការនិយាយពីទ្រឹស្តីកសិកម្មថ្មីនៅ វត្ត មង្គលចៃផាត់ថាណា ដែលព្រះមហាក្សត្ររបស់គាត់បានទុកដីដោយឡែកមួយដើម្បីធ្វើជាគំរូសំរាប់គោលការណ៍នេះ រៀងរាល់ពេលដែលគាត់ទៅចូលរួមក្នុងព្រឹតិការណ៍នេះ គាត់បានត្រឡប់មកផ្ទះវិញហើយបានកែប្រែទ្រង់ទ្រាយដីរបស់គាត់ ជាពិសេសគឺការបង្កើតកន្លែងសំរាប់ទឹកដែលអាចទុកបានសំរាប់ការប្រើប្រាស់ ហើយផ្លាស់ប្តូរគាត់ពីការធ្វើកសិកម្មតែមួយមុខទៅជាកសិកម្មចំរុះវិញ។

## ការជីកអាងទប់ទឹកទាំងជ្រៅនិងរាក់ សូមអោយវាហូរទៅតាមដីរបស់អ្នកជុំវិញ " កូនអូរដូចជាពោះវៀនមាន់របស់អ្នកនឹងផ្តល់ទឹកអោយអ្នកគ្រង់កន្លែង

ដោយព្រោះទឹកពិតជាកត្តាមានសារៈសំខាន់ណាស់សំរាប់កសិកម្ម ការជដែកនៅវត្ត មង្គលជ័យ ផាថាណា បានធ្វើអោយគាត់សំរេចចិត្តពង្រីកអាងទប់ទឹករបស់គាត់ធំឡើង ហើយត្រូវជីកអាងទប់ទឹកថ្មី ដើម្បីអោយគាត់មានដីនៅសល់ត្រឹមតែ៩រ៉ៃប៉ុណ្ណោះសំរាប់ធ្វើកសិកមម្មសំរាប់ការប្រើប្រាស់ក្នុងគ្រួសារ តែនៅពេលដែលគាត់ជីកអាងទប់ទឹកជាលើកដំបូង គាត់នៅខ្វះចំណេះដឹងជាច្រើនហើយនិងការយល់ដឹងផ្នែកការជីកអាងទប់ទឹក។ អ្វីដែលគាត់ដឹងគឺត្រូវប្រើគ្រឿងចក្រជិកដីចុះក្រោមត្រង់

ជំរៅ៦ទៅ៧ម៉ែត្រ ជារាង៤ជ្រុងទ្រវែង វាមានភាពល្អគ្រប់គ្រាន់សំរាប់ការស្តុកទឹក តែវាជារឿងហ្នឹងហើយ។







រូបភាពទី១កន្លែងដែលជីកជាប្រឡាយសំរាប់យកទឹកដើម្បីបន្ថយល្បឿនទឹក រូបភាពទី២ អាងទឹកដែឡមានជំរៅផ្សេងគ្នាសំរាប់ត្រីពង រូបភាពទី៣ ដីដែលជីអាចធ្វើជាកូនភ្នំសំរាប់ដាំ ឈើរូបទី៤ ភ្លឺស្រែដែលលើកឡើងដើម្បីទប់ទឹកនិងដាំដុះ រូបភាពទី៥ ស្រះសំរាប់ទប់ទឹកទៀងទាត់

ក្រោយមក ពេលដែលគាត់ទៅសិក្សាជាមួយលោកសាស្ត្រាចារ្យ វិវ៉ាត់ សាលាយ៉ាកាំថន នៅមូលនិធិកសិធម្មជាតិ  គាត់បានយល់ថាអាងទឹកដែលល្អគួរតែមានលក្ខណៈដូចជាក្រឡុកដូចជាមានក្នុងធម្មជាតិ ដូចជាមានកំរិតជំរៅខុសៗគ្នា ដើម្បីអោយជីវិតដែលរស់នៅ ទាំងរុក្ខជាតិនិងសត្វ អាចរីកចំ

រើនខាងក្នុងបាន ជំនួសអោយការប្រើប្រាស់តែឯងដើម្បីស្តុកទឹក។ នៅពេលដែលគាត់ពង្រីកអាងទឹកម្តងទៀត នៅឆ្នាំនេះ គាត់បានជីកវាអោយត្រូវនឹងលក្ខណ្ឌនៃទឹកន្លែងនៅជុំវិញអោយបានច្រើនតាមដែលអាចធ្វើទៅបាន។

*"ទំហំដី២០រ៉ែនេះ កាលពីមុនខ្ញុំបានជីកប្រហែល១រ៉ៃ ដែលមានទាំងប្រឡាយជុំវិញកកសិដ្ឋានចំនួនប្រហែលជា៣រ៉ៃតែមិនបានជីកនៅកន្លែងដដែលទេ ។ ឆ្នាំនេះខ្ញុំបានជីកច្រើនថែមទៀតព្រោះយើងមិនមានទឹកគ្រប់គ្រាន់ ព្រោះឆ្នាំនេះយើងមានគ្រោះរាំងស្ងួត។ សូមមើលទីនេះ ទឹកដែលយើងប្រើប្រាស់សំរាប់រុក្ខជាតិនិងសត្វ សំរាប់ការប្រើប្រាស់ក្នុងគ្រួសារ វាបានរីងស្ងួតអស់។ វាពិតជាវិបត្តិធ្ងន់ធ្ងរណាស់។ប្រឡាយក្នុងកសិដ្ឋាន ទាំងអស់បានរីង ហើយទឹកក្នុងស្រះនៅសល់តែ១ម៉ែត្រ បើវាអូសបន្លាយតែកន្លះខែទៀត បើមិនមានការបង្ហូរទឹកពីធារាសាស្ត្រមកជួយយើងទេ យើងពិតជាស្លាប់។ យើងពិតជាមិនមានទឹកប្រើប្រាស់ទេ។ យើងមានវិធីសាស្ត្រឡាត់ក្របាំង នៃការគណនាថាយើងប្រើប្រាស់ទឹកប៉ុន្មាន តើទឹកប៉ុន្មានដែលយើងប្រើប្រាស់សំរាប់កសិដ្ឋានស្រូវ ទឹកប៉ុន្មាដែលយើងត្រូវការសំរាប់ការចិញ្ចឹមសត្វ រុក្ខជាតិ និងបន្លែបង្កា ដូច្នេះ១ប្លង់និយាយថាត្រូវការអាងទប់ទឹកជីកជ្រៅប៉ុណ្ណា ត្រូវការទឹកប៉ុណ្ណា។*

*នៅឆ្នាំនេះយើងបានជីកពីរប្លង់ថែមទៀត ព្រោះយើងឃើញថាបើមានគ្រោះរាំងស្ងួតទៀតដូចជាឆ្នាំមុន នឹងមិនមានទឹកគ្រប់គ្រាន់សំរាប់អាងទប់ទឹកធំតែមួយនោះ ដូច្នេះយើងក៏ជីកថែមទៀត ដើម្បីអោយយើងអាចមានទឹកដែលយើងអាចប្រើប្រាស់បាន ពេញមួយឆ្នាំ រាប់ទាំងរដូវណាដែលមិនមានភ្លៀងធ្លាក់ លោកសាស្ត្រាចារ្យ យ៉ាក និយាយថា ក្នុងចំនួន៣៦៥ថ្ងៃ មានតែ៦០ថ្ងៃទេដែលភ្លៀង ហើយ៣០០ថ្ងៃនឹងមិនមានទេ ហើយគាត់និយាយថា ទឹកនឹងបំភាយឡើងនូវចំហាយទឹកក្នុងកំរិត១ស.មក្នុងមួយថ្ងៃ ដូច្នេះយើងអាចឃើញថា អាងទប់ទឹកតែ៣ម៉ែត្រនឹងមិនគ្រប់គ្រាន់ឡើយ ព្រោះទឹកនឹង ភាយចំហាយឡើង។ ដូច្នេះយើងក៏បានបន្ថែមអាងទប់ទឹក ដើម្បីអោយយើងអាចផ្គត់ផ្គង់ចំនយនទឹកដែលត្រូវការដើម្បីប្រើប្រាស់ក្នុងដីរបស់យើង។*

*អាងថ្មីរបស់យើងមិនមានរាងបួនជ្រុងទេ ដូចជាអាងចាស់។ ពេលដែលខ្ញុំបានឃើញអាងទឹករបស់សាស្ត្រាចារ្យ យ៉ាក ឃើញការរចនាប្លង់របស់ឡាតក្របាំង គេមិនបានខ្ជះខ្ជាយទីកន្លែងឡើយ។ យើងជីកអាងដែលមើលទៅដូចជារាងដីរបស់យើង ពត់ពេន បត់បែន។ យើងបានដាំបន្លែ និងរុក្ខជាតិដែលអាចហូបបាននៅតាមមាត់វា ហើយពង្រីកអោយបានធំតាមអាងបួនជ្រុងរបស់យើង តែយើងមិនបានខ្ជះខ្ជាយទីកន្លែងទំនេរឡើយ អាងរបស់យើងមានរាងវែង ជ្រៅ យើងអាចឃើញត្រីពង ដូចជាត្រីទីឡាប់យ៉ា ត្រីមាស មិនពងនៅក្នុងទឹកជ្រៅទេ។*

*ពួកវារស់នៅក្នុងទឹករាក់ មិនជ្រៅជាង២ម៉ែត្រទេ ពួកវាលូតលាស់បានល្អ ហើយធំលឿន ព្រោះវាត្រូវការងើបនិងដកដង្ហើមក្នុងទឹកកំរិតនេះ។ រុក្ខជាតិក្នុងទឹក ដែលមាន បើទឹកជ្រៅពេកយើងនឹងមិនមានសំរាប់ហូបទេ វាល្អបានតែទប់ទឹក តែបើយើងមានអាងដែលរាក់ជាង រុក្ខជាតិទឹកជាច្រើននឹងលូតលាស់បាន ដូចជាផាន់ដាននិងរុក្ខជាតវល្លិទឹក។វាលូតលាស់បាននៅជំរៅប្រហែល១ម៉ែត្រ នេះមានន័យថាជាប្រភពអាហារសំរាប់យើងនៅក្នុងអាងទឹករបស់យើង បូកទាំងពួកវាមានការការពារមិនអោយមានការដួលឡើយ បើអ្នកមើលទៅលើអាងដំបូងដែលយើងជីក វាអត់មានរុក្ខជាតិដុះលូតលាស់ទេ អត់មានត្រកួន អ្វីដែលមានគឺទឹកតែម្យាង តែបើអ្នកមកមើលកន្លែងដែលរាក់ជាង អ្នកនឹងឃើញអាហារ ក៏ដូចជាកន្លែងផ្សេងដែលត្រូវដាក់ទឹករបស់យើង។*

អាងទឹកថ្មីដែលយើងជីកមាន៣ជំរៅ អាងមួយដែលរាក់ ១ទៅ១ម៉ែត្រកន្លះ មួយកណ្តាលមានកំរិត២ទៅ៣ម៉ែត្រ និងមួយជ្រៅពី៤ទៅ៥ម៉ែត្រទៅ៨ទៅ៩ម៉ែត្រ។ អាងនេះបំពេញទឹកអោយអូរពោះវៀនមាន់ឬអូរតូចៗជាងដែលតភ្ជាប់វា វាផ្តល់ទឹកដល់រុក្ខជាតិទាំងអស់នៅលើដី អ្វីសព្វយ៉ាងដែលមាននៅក្នុងវាលស្រែ សួនដំណាំ ប្លង់ឈើហូបផ្លែ ព្រៃឬស្សី គ្រប់មួយឆ្នាំ។

ក៏ដូចជាទឹកភ្លៀង ហើយនឹងទឹកពីប្រឡាយបង្ហូរ ដែលអាចអោយយើងបង្ហូរទៅក្នុងដីរបស់យើងបាន មានប្រភពទឹកមួយទៀតដែលលោកប៊ុនលោមអាចប្រមូលប្រើបាន ទឹកដែលគេមិនបានប្រមូលនៅជុំវិញដី ទឹកនេះមានទំហំធំ ធំដល់ទៅ២ដងនៃទឹកដែលគាត់ប្រមូល។

*"សំរាប់តំបន់នេះ យើងបានគណនាឃើញថាយើងអាចប្រមូលបានទឹក៣០០% ដំបូងទំហំនៃទឹកភ្លៀងនៅក្នុងខេត្តសាក៉កបូរីចំនួន ១២០០ម៉ែត្រគឺបក្នុងមួយឆ្នាំ ទី២ ទឹកពីទំនប់ដែលគេបង្ហូរទៅផ្ទៃគទី២ ហើយទី៣ ទឹកពីមនុស្សដែលមិនប្រមូលថា យើងទទួលបានវានៅទីនេះ ពួកគេមិនមានអាងស្តុកទឹកទេ ដូច្នេះយើងបានយកទឹកទាំងអស់ទៅកាន់ដីរបស់យើង។ យើងក៏បានជីកហើយដៃរន្ធូវប្រឡាយទឹកនៅខាងក្រៅជុំវិញដីរបស់យើង ដូច្នេះយើងមានប្រឡាយទឹកគ្រប់ទីកន្លែង។ទោះជាយ៉ាងណាក៏ដោយ ដំបូងទឹកត្រូវតែឆ្លងកាត់ប្រឡាយតូចៗសិននៅលើក្បាលដីរបស់យើង ហើយនិងត្រូវបានត្រងយក។ យើងប្រើប្រាស់គោលការណ៍ភូមិរ៉ាក់ ៖ទុកអោយបីសាចបង្ក្រាប់គ្នាវា យើងប្រើប្រាស់កំផ្លោកសំរាប់ជាចំរោះទឹក។ ហើយអាងទឹកដទៃទៀតជាអាងបែបដី ដែលយើងប្រើដីជាភ្នាក់ងារតំរងទឹក។ យើងក៏បន្ថែម ទឹកជី(น้ำหมักรสจืด) និងបណ្តូលចេកសំរាប់ជាមីក្រូសរីរាង្គជារៀងរាល់២ខែម្តង ដើម្បីបន្ថែដល់លក្ខណ្ឌទឹក" លោកគី ប៊ុនលោមនិយាយ។*

**លើកភ្លឺទំនប់ពីដី ស្តុកទឹកទុក ភ្លឺធំ បន្លែដែលអាចហូបបាន**

ក៏ដូចជាការស្តុកទឹកនៅក្នុងអាងទឹកដែរ វាលស្រែនិងកូនភ្នំក៏អាចត្រូវបានប្រើប្រាស់ដើម្បីប្រមូលទឹកដែរ។

*"នៅពេលដែលយើងអនុវត្តន៍គំនិតថ្មីជាលើកដំបូង យើងបានបែងចែកដីរបស់យើង ដើម្បីជីកអាងស្តុកទឹក សំរាប់ការធ្វើស្រែ ដាំបន្លែ ចិញ្ចឹមសត្វ និងការរស់នៅ។ ជាដំបូងយើងគិតថា អាងរបស់យើងនឹងផ្អែកទៅលើទឹកពីធារាសាស្ត្រ ដែលបើកបង្ហូរមកនិងទឹកភ្លៀង ដែលអាចអោយអាងយើងពេញបាន តែនៅឆ្នាំ២០១១មានទឹកជំនន់ វាបានលិចលង់ ទឹកលិចទាំងអស់ហូរហៀរ ហើយយើងមិនដឹងដោះស្រាយវិបត្តិនេះដោយរបៀបណាឡើយ។ពេលនេះនៅក្នុងឆ្នាំនេះ វាមិនមានភ្លៀងទេ ហើយមិនមានទឹកទេនៅក្នុងទំនប់ទឹក ដោយសារតែអត់មានទឹកក្នុងទំបន់ គេមិនអាចបង្ហូរទឹកអោយយើងបានទេ ដូច្នេះយើងប្រឈមមុខនឹងគ្រោះរាំងស្ងួត ហើយកាលពី៣ឆ្នាំមុន ខ្ញុំបានរៀនបានទាក់ទងនឹង ការធ្វើតាមគន្លងរបស់ព្រះមហាក្សត្រ ដែលយើងលើកជាកូនភ្នំ អាងទប់ទឹក និងគំរូស្រែ។*

*អាងទប់ទឹក ការជីកអាងនិងការគិតគណនាអាស្រ័យលើតំបន់របស់អ្នកដែលបានធ្វើផ្អែកតាមគោលការណ៍របស់ឡាត់ក្របាំង។ អ្នកអាចយកការនេះហើយគណនាថាអ្នកមានដីប៉ុន្មាន ហើយតើអ្នកត្រូវជីកអាងប៉ុន្មា ហើយជ្រៅប៉ុន្មា ដើម្បីអោយមានទឹកគ្រប់គ្រាន់សំរាប់តំបន់ពិសេសរបស់អ្នក។ នៅពេលអតីតកាលដីភ្លឺលើមានភាពតូចហើយខ្លី ហើយបានត្រឹមតែជួយដល់ស្រូវ។ វាមិនត្រូវបានគិតសំរាប់ការរក្សាទឹកទុកប្រើប្រាស់ឡើយ ដូច្នេះយើងតែងតែបូមទឹកចូលទៅក្នុងស្រែរបស់យើង។ តែក្រោយមកខ្ញុំបានដឹងថា វាត្រូវការធំជាងនេះ។ ភ្លឺត្រូវតែលើកអោយបាន១ម៉ែត្រទទឹងនិងកំពស់១ម៉ែត្រ ដំបូងខ្ញុំឆ្ងល់ថាហេតុអីក៏ត្រូវលើកខ្ពស់ម្លេះ*

*តែក្រោយមកខ្ញុំបានយល់ពីគោលការណ៍ ក៏ដូចជាជួយអោយយើងអាចប្រមូលទឹកនៅក្នុងវាលស្រែ ការលើកភ្លឺអោយកាន់តែធំ មានន័យថាយើងអាចដាំដុះ បន្លែនៅទីនោះ ឬរុក្ខជាតិដែលអាចហូបបានឬរុក្ខជាតិមានប្រយោជន៍ដែលយើងចង់ដាំ។ ជំនួសអោយការលើកភ្លឺធម្មតាដែលអាចជួយទុកទឹក យើងក៏មានក្រុមរុក្ខជាតិទាំងអស់នេះដែរ ដែលនាំមកនូវគុណប្រយោជន៍ដល់យើង។ ដូច្នេះនៅក្នុងស្រែមួយយើងមិនត្រឹមតែមានតែស្រូវប៉ុណ្ណោះទេ តែមានទាំងដំណាំនៅលើភ្លឺដែរ យើងមានអាហារ ហើយយើងមានចំណូលអំឡុងពេល៩ខែដែលយើងចំណាយពេលមើលស្រូវរបស់យើង។ យើងបានបង្វិលដំណាំនេះទៅជាចំណូល យើងទៅមើលស្រូវរបស់យើងជាផ្នែកមួយនៃអ្វីដែលយើងបានធ្វើ នៅលើភ្លឺស្រែយើងមានអ្វីច្រើនជាងស្រូវទៅទៀត។*

*ជាមួយនឹងភ្លឺខ្ពស់ យើងក៏មានកំរិតទឹកខ្ពស់ដែរ ស្មៅចង្រៃមិនលូតលាស់ទេនៅក្នុងស្រែរបស់យើង ដោយសារវាលិចទឹក ដូច្នេះស្រូវបានលូតលាស់ឡើង កាន់តែខ្ពស់ទៅៗ ឈានដល់កំរិតនៃទឹក*

*ដូច្នេះហើយវាជាវិធីដ៏ល្អមួយក្នុងការគ្រប់គ្រងស្មៅដែលមិនចង់អោយមាន ដោយមិនចាំបាច់បាញ់ថ្នាំសំលាប់នៅក្នុងស្រែរបស់យើងទេ យើងធ្វើកសិកម្មបែបសរីរាង្គ"។*

**កន្លែងដែលត្រូវរៀបចំត្រូវគិតដល់ដី ទឹក ខ្យល់ ភ្លើង និងមនុស្ស**

*សំរាប់អ្នកដែលមានដីពួកគាត់ចង់រចនាឡើងវិញដើម្បីអោយគាត់អាចគ្រប់គ្រងចាត់ចែងទឹកអោយមានប្រសិទ្ធិភាពនិងការប្រើប្រាស់ដី នៅទីនេះមានគោលការណ៍មួយចំនួនដែលចាំបាច់ត្រូវគិតពិចារណា។*

*" កត្តាសំខាន់នៃការទទួលបានតំបន់របស់អ្នកគឺ ដី ទឹក ខ្យល់ ភ្លើង និងមនុស្ស។ដី៖ អ្នកត្រូវអង្កេតមើលថាដីអ្នកជាដីប្រភេទណា ទឹក៖ តើទឹករបស់អ្នកហូរទៅចំណុចណានៅលើដីរបស់អ្នក ហើយហូរមកពីណា ខ្យល់៖ នេះមានសារៈសំខាន់ណាស់សំរាប់ផ្ទះរបស់អ្នក ខ្យល់មកពីពីរទិសដៅ ខ្យល់មកពីទិសខាងត្បូងឈៀងខាងលិច បក់ជាភ្លៀង និងខ្យល់ពីខាងជើង ខ្យល់ត្រជាក់ ខ្លះមកពីទិសខាងជើងឈៀងខាងកើត។ នៅពេលដែលខ្យល់បក់ពីខាងជើង យើងដឹងថាវាជាពេលដែលត្រូវច្រូតកាត់ស្រូវ ប្រហែលខែធ្នូ មករា វានឹងបក់កំទេចកំទីស្រូវចូលផ្ទះ ហើយយើងហៅវាថាជាខ្យល់ស្រូវដំបូង។ ប្រសិនបើយើងដាំដុះរុក្ខជាតិនៅចំការ ហើយសាងសង់ផ្ទះរបស់យើងនៅក្នុងទិសដៅនេះ យើងនឹងពេញដោយកំទេចកំទីស្រូវ។ ឬបើយើងសង់ផ្ទះរបស់យើងនៅកន្លែងផ្សេងដែលទទួលបានពន្លឺព្រះអាទិត្យទាំងពីរផ្នែក ទាំងខាងកើតនិងខាងលិច វានឹងក្តៅគ្រប់ពេល។*

*"ភ្លើងមានន័យថាពន្លឺថ្ងៃ ឆ្ពោះទៅខាងកើតនិងខាងលិចយើងគួរដាំដើមឈើ នៅកន្លែងណាដែលគេត្រូវការវា សូមកុំអោយផ្ទះរបស់អ្នកក្តៅគ្រប់ពេលនោះឡើយ។ នៅក្នុងវាលស្រែរបស់យើង យើងក៏អាចដាំដើមហូបផ្លែបានដែរ បើយើងដាំទៅខាងកើតនិងខាងលិច ម្លប់នៃដើមឈើនិងបានដល់ស្រែរបស់យើង បង្កើតជាម្លប់ត្រជាក់។ បើយើងដាំនៅខាងត្បូងនិងខាងជើង ពន្លឺព្រះអាទិត្យនិងកាត់តាមពីលើភ្លឺស្រែ ហើយម្លប់នឹងមិនអាចបានដល់ស្រែឡើយ ដូច្នេះហើយអ្នកអាចដាំរុក្ខជាតិដើមឈើខ្ពស់ទាំងអស់នៅខាងជើងនិងត្បូង តែខាងកើតនិងខាងលិចគួរដាំដើមឈើទាបៗ។*

" កត្តាសំខាន់គឺមនុស្ស ការរចនារៀបចំឡើងត្រូវអោយបានពេញចិត្តមនុស្សដែលរស់នៅទីនោះ សូមយកទ្រឹស្តីនេះយើងមើលថាតើមនុស្សត្រូវការធ្វើអ្វី ហើយរបៀបណា ប្រសិនបើយើងធ្វើតាមការគិតទាំងអស់សំរាប់ពួកគេ វាមានន័យថា គេមិនចូលចិត្តកន្លែងដែលយើងរចនាឡើយ ដូច្នេះវាត្រូវប្រាកដថាកត្តាមនុស្ស មានសារៈសំខាន់បំផុតក្នុងចំណោមទាំងអស់" លោក ប៊ុនលោម និយាយអំពីគោលការណ៍នៃការរចនា។

**គ្រប់ផ្ទះគួរតែមានអាងរាងជាដូង ដែលគេអាចប្រមូលទឹកបានច្រើនដូចជាទំបន់ទឹកដែរ**
ផលប្រយោជន៍ពីការចាត់ចែងទឹកនិងដីអាស្រ័យទៅលើគោលការណ៍នៃកូនភ្នំ អាងទឹក និងគំរូស្រែ ក្រៅពីការផលិតបានលទ្ធផលល្អហើយ សំរាប់ម្ចាស់ដី វានឹងបង្កើតបានជាលទ្ធផលល្អនៅក្នុងកំរិតតំបន់ដែរ ហើយនិងថ្នាក់ជាតិដែរ។

*"ការបង្កើតកូនភ្នំ អាងទឹកនិងស្រែទាំងអស់ជាទម្រង់នៃការរក្សាទឹកទុក។ វានឹងជួយបានទាំងទឹកជំនន់និងគ្រោះរាំងស្ងួត។ បើមានទឹកជំនន់ យើងអាចបង្ហូរទឹកចូលហើយរក្សាទុកនៅលើដីរបស់យើង យើងមានកន្លែងដែលអាចធ្វើបាន ហើយវានឹងមិនហូរចុះហើយប៉ះដល់មនុស្សនៅបាងកក បើយើងអាចអនុវត្តន៍បានជារួមនៅក្នុងគំរូនេះប្រហែលជារាប់រយពាន់ដងនៅក្នុងអាងទឹកផាសាក់ វាអាចនឹងស្មើទៅនឹងកាប៉ាស៊ីតេនៃទំបន់ផាសាក់។ យើងមានទំនប់ ដោយមិនបំផ្លាញដល់ព្រៃឈើ ដោយមិនទន្ទ្រានដី ដោយមិនធ្វើអោយប៉ះពាល់ដល់ប្រជាជនសហគមន៍ដែលរស់នៅលើដីនោះ ដោយគ្មានការតវ៉ាប្រឆាំងអ្វីទាំងអស់ ដោយការប្រើប្រាស់តែដីដែលយើងមានស្រាប់ ហើយអ្វីបន្ថែមទៀត ដីដែលយើងប្រើប្រាស់សំរាប់វានឹងនាំមកនូវប្រយោជន៍ដល់យើង បើយើងអាចធ្វើបានកាន់តែច្រើនជាងនេះ យើងនឹងមានភាពស្មើគ្នាទៅនឹងទំនប់ទឹកដ៏ធំ ឬក៏អ្នកប្រហែលជាធ្វើអាងទប់ទឹកដែលមានទំហំមធ្យមបាន វានៅតែជួយយើងអោយរួចផុតពីបញ្ហាធំៗ នៅពេលដែលវាភ្លៀងទឹកនឹងបំពេញអាងរបស់យើង។*

*"រឿងមួយទៀត ទ្រឹស្តីពី អាងទឹករាងដូងនេះ នៅពេលដែលវាភ្លៀងទឹកនឹងនៅក្នុងអាងនីមួយៗ ឬអាងដូចថាស ដូចដែលលោកសាស្ត្រាចារ្យ យ៉ាក និយាយថា បើខេត្តសារ៉ាកបូរីជាខេត្តដែលមានរាងដូចជាដូង ហើយគ្រប់កន្លែងអាចដក់ទឹកបាន ខ្លះជ្រៅហើយខ្លះទៀតរាក់ អាស្រ័យទៅតាមដីរបស់គេម្នាក់ៗទឹកនឹងមិនលិចជន់ទេហើយក៏មិនពន្លិចមនុស្សនៅបាងកកដែរ តែនៅពេលនេះយើងបានបំពេញអាងរបស់យើងអស់ហើយដើម្បីកាត់បន្ថយដីអោយនៅតិច ដូច្នេះទឹកហូរហៀរនៅកន្លែងដែលទំនាប ទឹកនឹងហូរទៅតាមអាងនីមួយៗ វានឹងពង្រាយ វានឹងស្តុកទុកនៅក្នុងតំបន់សារ៉ាក់បូរី។*

*តំបន់ដែលនៅក្រោមយើងនឹងមិនមានប៉ះទឹកជំនន់ទេ ការនេះអាចធ្វើបានដោយសារតែយើងមានអាងទុកទឹកដោយខ្លួនឯងសំរាប់ការប្រើប្រាស់នៅពេលក្រោយទៀត ទោះបីជាអូរ ភ្លឺស្រែ នៅក្នុងវាលស្រែក៏ដោយ ទោះបីជាកូនភ្នំក៏អាចប្រមូលទឹកបានដែរ ដោយការដាំកូនឈើផ្សេងៗ ដូចជាភ្នំនៅពេលដែលមានភ្លៀង ស្រូបយកទឹកទៅក្នុងដីរបស់វា ហើយក៏ជ្រាបចូលក្នុងដីបន្តិចម្តងៗ ផ្លាស់ប្តូរទៅជាដំណក់ ដើមឈើនីមួយៗបានបញ្ចេញតំណក់ទឹក មួយតំណក់ៗ ក៏បានក្លាយទៅជាស្ទឹងបឹងបួរ ហើយហូរចុះទៅតាមភូមិ។*
ការលះបង់ដីសំរាប់កសិកម្មដើម្បីទុកទឹកនៅក្នុងទម្រង់ជាអាងស្តុកទឹក វាលស្រែ និងកូនភ្នំ ក្រៅពី

វិធីដើម្បីទទួលបានទឹកគ្រប់គ្រាន់សំរាប់ខ្លួនឯងហើយ វាក៏ជាវិធីមួយដែលអាចលើកកំពស់ប្រសិទ្ធិភាពនៃការគ្រប់គ្រងទឹកនៅក្នុងរូបភាពដ៏ធំដែរ។ វាសមនឹងទទួលបានការវិនិយោគដែលកសិករគួរគួពិចារណា។



រូបទី៦និង៧គឺជាពាងនិងធុងទឹកសំរាប់ផ្ទះមានដីតូច ហើយរូបទី៨និង៩គឺជាអាងទឹកធ្វើពីឬស្សីប្លុកស៊ីម៉ង់និងទំនប់ទឹកដើម្បីបង្ហូរនិងបន្ថយល្បឿនទឹកហូរ

បើចាប់អារម្មណ៍ សូមចូលមើលតំបន់នេះហើយសួរនាំសំរាប់ព័ត៌មានបន្ថែម។ លោកប៊ុន លោមតៅកែវ អាចទាក់ទងបាន នៅភូមិ ៨៩/២ ភូមិ៧ ឃុំណងនូ ស្រុកមឿង ខេត្តសារ៉ាក់បូរី ១៨០០០ ទូរស័ព្ទ08 9050 1812.

**រូបភាព (ពីលើទៅក្រោម ឆ្វេងទៅស្តាំ)**

1. អាងទឹកដំបូងដែលបានជីកសំរាប់ការទុកទឹក ជារាងបួនជ្រុង

2. អាងទឹកបន្ថែមទៀតដែលបានជីកនៅក្នុងឆ្នាំនេះ វាហូរវិលជុំវិញជាមួយនឹងលក្ខណះដី ហើយមានជំរៅខុសៗគ្នា ដែលយកតាមលក្ខណះធម្មជាតិ

3. ប្រឡាយបង្ហូរទឹកខ័ណ្ឌព្រំដីដែលប្រមូលទឹកពីទីជុំវិញ ក៏ដូចជាជួយកំណត់ព្រំប្រទល់ដីដែរ។

4. Chicken guts canals or irrigation ditches help distribute water throughout the property. កូនអូររាងដូចពោះវៀនមាន់ ឬធារាសាស្រ្តជួយចែកចាយទឹកទៅដល់ដីទាំងមូល

5. នៅក្នុងប្រឡាយធារាសាស្រ្តកង្កែបអាចត្រូវបានចិញ្ចឹមសំរាប់ការហូបចុកនិងលក់ដូរ ដាំកំផ្លោក ដើម្បិលើកកំពស់ទឹក ផ្សិតចំបើងក៏អាចត្រូវបានប្រមូលផលដាក់ក្នុងល្អិ

6. គំរូកូនភ្នំបានដាំដំណាំបន្លែនិងឈើរស់យូរ ផ្ទះក៏អាចសង់នៅទីនេះដែរសំរាប់ជាទីជំរកពេលមានទឹកជំនន់

7. លើកភ្លឺស្រែអោយបានកំពស់១ម៉ែត្រ នៅពេលដែលទឹកជន់លិចស្រែរបស់អ្នកយើងអាចទុកទឹកបាន

8. នៅពេលដែលមានទឹកលើសលប់ ដំណាំបន្លែនិងដើមឈើ កសិដ្ឋានរបស់អ្នកនឹងខៀវស្រងាត់

### ដ្យាក្រាមរបស់លោក ប៊ុន លោម តៅកែវ

1. ស្រូវ (ពូជចឹកចឹយ)
2. បន្លែ ដូចជា ននោង ម្ទេស
3.. ធុងអណ្តែតទឹកសំរាប់ចិញ្ចឹមកង្កែប
4. ឬស្សី
5. ប្រឡាយបង្ហូរទឹកសំរាប់ដំណាំឈើហូបផ្លែ ដូចជា ម៉ាក់ប្រាង ចេក ត្របែក មានដាំខ្ទឹមនៅចន្លោះៗ និងត្រប់។
6. គ្រោងសំរាប់ដាំដុះផ្សិតខ្យង
7. ធុងអណ្តែតទឹកសំរាប់ចិញ្ចឹមកង្កែប
8. ទ្រុងមាន់
9. អាងមួយទៀត
10. សួនដំណាំស្វាយដែលបានរៀបចំសំរាប់ការដាំដុះដែលអាចផ្តល់វិធីសាស្រ្តដែលអាចរៀនបានទាក់ទងនឹងថ្នាំបូរាណនិងពូជនានា។
11. ផ្ទះមួយដែលអាចប្រើប្រាស់ក្នុងគោលបំណងច្រើនបាន
12..ផ្ទះ
13. អាងទឹកមានរាងបួនជ្រុងទ្រវែង
14.. ប្រឡាយបង្ហូរទឹក ឬកូនអូរមានរាងដូចពោះវៀនមាន់
15.. សួនដំណាំ ដូចជាស្ពៃ ស្ពៃខេល ត្រកួន ម្រះព្រៅនិងជីក្រហម
16.. អាងទឹក
17. កូនភ្នំផ្អែកលើគំរូ